មើលវីដេអូ ភាគទី ១៦

# យុគលធម៌ ៦ គូ

យុគលធម៌គូទី ១ : ៨-កាយបស្សទ្ធិ ៩-ចិត្តបស្សទ្ធិ

**(Tranquility of mental states and Tranquility of mind)**

ពាក្យថា កាយបស្សទ្ធិ បានដល់ សេចក្ដីស្ងប់នាមខន្ធ ៣ គឺ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ចិត្តបស្សទ្ធិ បានដល់ ស្ងប់វិញ្ញាណក្ខន្ធ។

កាយស្ស បស្សម្ភនំ = កាយបស្សទ្ធិ សេចក្ដីស្ងប់កាយ (នាមខន្ធ ៣) ឈ្មោះថា កាយបស្សទ្ធិ។ ចិត្តស្ស បស្សម្ភនំ = ចិត្តបស្សទ្ធិ សេចក្ដីស្ងប់ចិត្ត (វិញ្ញាណក្ខន្ធ) ឈ្មោះថា ចិត្តបស្សទ្ធិ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់បស្សទ្ធិ

១ - **កាយចិត្តានំ ទរថវូបសមលក្ខណា** មានការស្ងប់កាយ (នាមខន្ធ ៣) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាលក្ខណៈ

២ - **កាយចិត្តទរថនិម្មទ្ទនរសា** មានការកំចាត់បង់ភាពក្តៅក្រហាយ របស់កាយនិង ចិត្ត ជាកិច្ច

៣ - **កាយចិត្តានំ អបរិប្ផន្ទនសីតិភាវបច្ចុប្បដ្ឋានា** មានភាពស្ងប់ ត្រជាក់មិនក្តៅផ្សានៃកាយ និងចិត្ត ជាអាការប្រាកដ

៤ - **កាយចិត្តបទដ្ឋានា** មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

*បស្សទ្ធិ ជាបដិបក្ខនឹង ឧទ្ធច្ចៈ។*

## យុគលធម៌គូទី ២ :  ១០ - កាយលហុតា ១១ - ចិត្តលហុតា

(Lightness of mental states and Lightness of mind)

កាយស្ស លហុភាវោ = កាយលហុតា សេចក្ដីស្រាលនៃកាយ ឈ្មោះថា កាយលហុតា។

ចិត្តស្ស លហុភាវោ = ចិត្តលហុតា សេចក្ដីស្រាលនៃចិត្ត ឈ្មោះថា ចិត្តលហុតា។

# លក្ខណាទិចតុក្កៈរបស់លហុតា

១ - កាយចិត្តគរុភាវរូបសមលក្ខណា មានការស្ងប់ភាពធ្ងន់របស់កាយនិង ចិត្ត ជាលក្ខណៈ

២ - កាយចិត្តគរុភាវនិម្មទ្ធនរសា មានការកំចាត់បង់ភាពធ្ងន់របស់កាយនិង ចិត្ត ជាកិច្ច

៣ - កាយចិត្តានំ អទន្ធតាបច្ចុប្បដ្ឋានា មានការមិនយឺតយូរ (រហ័សរហួន) របស់កាយនិង ចិត្ត ជាអាការប្រាកដ

៤ - កាយចិត្តបទដ្ឋានា មានកាយ និងចិត្ត ជាហេតុជិត។

*លហុតា ជាបដិបក្ខនឹង ថីនមិទ្ធៈ។*

## យុគលធម៌គូទី ៣ :  ១២ - កាយមុទុតា ១៣ - ចិត្តមុទុតា

(Pliancy of mental states and Pliancy of mind)

កាយស្ស មុទុភាវោ = កាយមុទុតា ភាពទន់ភ្លន់នៃកាយ ឈ្មោះថា កាយមុទុតា។

ចិត្តស្ស មុទុភាវោ = ចិត្តមុទុតា ភាពទន់ភ្លន់នៃចិត្ត ឈ្មោះថា ចិត្តមុទុតា។

# លក្ខណាទិចតុក្កៈរបស់មុទុតា

១ - កាយចិត្តថទ្ធភាវរូបសមលក្ខណា មានការស្ងប់ភាពរឹងត្អឹងរបស់កាយ និង ចិត្ត ជាលក្ខណៈ

២ - កាយចិត្តថទ្ធភាវនិម្មទ្ទនរសា មានការកំចាត់បង់ភាពរឹងត្អឹងរបស់កាយនិង ចិត្ត ជាកិច្ច

៣ - អប្បដិឃាតបច្ចុប្បដ្ឋានា មានភាពមិនជំទាស់ (មិនចង្អៀតចង្អល់) ជាអាការប្រាកដ

៤ - កាយចិត្តបទដ្ឋានា មានកាយ និងចិត្ត ជាហេតុជិត។

*មុទុតា ជាបដិបក្ខនឹង មានៈ។*

## យុគលធម៌គូទី ៤ : ១៤ - កាយកម្មញ្ញតា ១៥ - ចិត្តកម្មញ្ញតា

(Adaptability of mental states and Adaptability of mind)

កាយស្ស កម្មញ្ញភាវោ = កាយកម្មញ្ញតា សេចក្តីគួរដល់ការងារនៃកាយ ឈ្មោះថា កាយកម្មញ្ញតា។

ចិត្តស្ស កម្មញ្ញភាវោ = ចិត្តកម្មញ្ញតា សេចក្តីគួរដល់ការងារនៃចិត្ត ឈ្មោះថា ចិត្តកម្មញ្ញតា។

# លក្ខណាទិចតុក្កៈរបស់កម្មញ្ញតា

១ - កាយចិត្តានំ អកម្មញ្ញភាវរូបសមលក្ខណា មានការរម្ងាប់កាយ និងចិត្ត ដែលមិនគួរដល់ការងារ ជាលក្ខណៈ

២ - កាយចិត្តកម្មញ្ញភាវនិម្មទ្ទនរសា មានការកំចាត់បង់នូវភាព មិនគួរដល់ការងាររបស់ កាយនិងចិត្ត ជាកិច្ច

៣ - កាយចិត្តានំ អារម្មណករណសម្បត្តិបច្ចុប្បដ្ឋានា មានការដល់ព្រមក្នុងការធ្វើអារម្មណ៍ឲ្យកាយ និងចិត្ត ជាអាការប្រាកដ

៤ - កាយចិត្តបទដ្ឋានា មានកាយ និងចិត្ត ជាហេតុជិត។

*កម្មញ្ញតា ជាបដិបក្ខនឹង នីវរណៈដែលនៅសល់។*

## យុគលធម៌គូទី ៥ : ១៦ - កាយបាគុញ្ញតា ១៧ - ចិត្តបាគុញ្ញតា

(Proficiency of mental states and Proficiency of mind)

កាយស្ស បាគុញ្ញភាវោ = កាយបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃកាយ ឈ្មោះថា កាយបាគុញ្ញតា។

ចិត្តស្ស បាគុញ្ញភាវោ = ចិត្តបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃចិត្ត ឈ្មោះថា ចិត្តបាគុញ្ញតា។

# លក្ខណាទិចតុក្កៈរបស់បាគុញ្ញតា

១ - កាយចិត្តានំ គេលញ្ញរូបសមលក្ខណា មានការស្ងប់នូវអាពាធនៃកាយ និង ចិត្ត ជាលក្ខណៈ

២ - កាយចិត្តគេលញ្ញនិម្មទ្ទនរសា មានការកំចាត់បង់នូវអាពាធនៃកាយ និង ចិត្ត ជាកិច្ច

៣ - និរាទីនវបច្ចុប្បដ្ឋានា មានការប្រាសចាកទោសជាអាការប្រាកដ

៤ - កាយចិត្តបទដ្ឋានា មានកាយ និងចិត្ត ជាហេតុជិត។

*បាគុញ្ញតា ជាបដិបក្ខនឹង អស្សទ្ធា (ការមិនមានសទ្ធា) ដែលជាអាពាធនៃចិត្តនិងចេតសិក។*

យុគលធម៌គូទី ៦ : ១៨ - កាយុជុកតា ១៩ - ចិត្តុជុកតា

(Rectitude of mental states and Rectitude of mind)

កាយស្ស ឧជុកភាវោ = កាយុជុកតា សេចក្ដីស្មោះត្រង់នៃកាយ ឈ្មោះថា កាយុជុកតា។

ចិត្តស្ស ឧជុកភាវោ = ចិត្តុជុកតា សេចក្ដីស្មោះត្រង់នៃចិត្ត ឈ្មោះថា ចិត្តុជុកតា។

# លក្ខណាទិចតុក្កៈរបស់ឧជុកតា

១ - កាយចិត្តានំ អជ្ជវ លក្ខណា — មានភាពស្មោះត្រង់នៃកាយ និង ចិត្ត ជាលក្ខណៈ

២ - កាយចិត្តកុដិលភាវនិម្មទ្ទនរសា — មានការកំចាត់បង់នូវសេចក្តីមិនស្មោះត្រង់នៃកាយ និង ចិត្ត ជាកិច្ច

៣ - អជិម្ហតាបច្ចុប្បដ្ឋានា — មានភាពត្រង់របស់កាយ និង ចិត្ត ជាអាការប្រាកដ

៤ - កាយចិត្តបទដ្ឋានា — មានកាយ និងចិត្ត ជាហេតុជិត។

*ឧជុកតា ជាបដិបក្ខនឹង មាយា និង សាថេយ្យៈ។*